គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia

និយ័តករបរធនបាលកិច្ច
Trust Regulator

លេខ ៣៦ ចេញផ្សាយថ្ងៃទី៧ ខែមីនា ឆ្នាំ២០២២
No. 36 Released on 7 March 2022

អត្ថបទប្រចាំសប្តាហ៍ | Weekly Article

# បរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច

## Trustor or Trust Contributor



រូបភាព | Image: Forbes Advisor
https://www.forbes.com/advisor/investing/trust-fund/

យោងតាមច្បាប់ស្តីពីបរធនបាលកិច្ច បរធនបាលទាយក សំដៅដល់បុគ្គលដែលបង្កើត និងកំណត់លក្ខខណ្ឌនៃបរធនបាល-កិច្ច និងផ្តល់ទ្រព្យសម្បត្តិឬមូលនិធិដំបូងទៅក្នុងបរធនបាលកិច្ច។ រីឯអ្នកផ្តល់វិភាគទានបរធនបាលកិច្ច សំដៅដល់បុគ្គលដែលផ្តល់វិភាគទានទៅក្នុងបរធនបាលកិច្ច ឬបរធនបាលកិច្ចដែលមានស្រាប់ និងមានសិទ្ធិចូលរួមកំណត់លក្ខខណ្ឌ នៃការបង់វិភាគទានដែលនឹងត្រូវគ្រប់គ្រងនិងចាត់ចែងដោយបរធនបាល និងលក្ខខណ្ឌ នៃការទទួលផលរបស់អត្ថគាហកៈ។

ដូចមានចែងក្នុងប្រការ៥ នៃប្រកាសស្តីពីវិធានក្នុងការគ្រប់គ្រង រៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច បរធន-បាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច អាចជារូបវន្តបុគ្គល ឬនីតិបុគ្គលមួយ ឬច្រើន។ បរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ចមួយ អាចស្នើសុំបង្កើតបរធនបាលកិច្ចច្រើនជាងមួយ ក្នុងប្រភេទដូចគ្នា ឬប្រភេទផ្សេងគ្នា។ ចំពោះបរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ចដែលមានចំនួនច្រើនជាងមួយវិញ ត្រូវមានកិច្ចព្រមព្រៀងរួមគ្នាក្នុងការយល់ព្រមបង្កើតបរធនបាលកិច្ច ព្រមទាំងស្នើសុំ និងទទួលបានការអនុញ្ញាតបង្កើតជាមុនពីនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**)។

In accordance with the Law on Trust, the trustor/settlor/grantor or the trust contributor refers to the individual who defines and sets out the terms of a trust and grants initial property or funds to the trust; whereas the trust contributor refers to the individual who contributes to the trust or the existing trust and has the right to participate in determining the terms of contribution payments managed and administered by the trustee and the terms of benefits the beneficiaries entitled to receive.

As stated in Article 5 of the Prakas on the Rules for the Management, Organization, and Functioning of the Trust, the trustor or the trust contributor may be one or multiple natural persons or juridical persons. A trustor or trust contributor is able to request an establishment of multiple trusts of the same or different types. Where there are more than one trustor or trust contributor, there shall be a mutual agreement to establish a trust as well as an approval by the Trust Regulator (**TR**) prior to establishing the trust.

អត្ថបទ៖ ភា សោភានាថ | Article: PHEA Sopheaneath

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.

www.facebook.com/trustregulatorcambodia www.trustregulator.gov.kh (855) 23 237 888
អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh